# ច្បាប់

# ស្តីពី

# វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ
លេខ: ៥១ ក្រ

# ក្រឹត្យ
# ក្រុមប្រឹក្សារដ្ឋ នៃ រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២។

## សំរេច

ប្រកាសអោយប្រើច្បាប់ ស្តីអំពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលរដ្ឋសភា នៃ រដ្ឋកម្ពុជា បានអនុម័ត នៅ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ១៩៩២ នាសម័យប្រជុំវិសាមញ្ញ នៃ នីតិកាលទី១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែ មេសា ឆ្នាំ ១៩៩២
ជ. ក្រុមប្រឹក្សារដ្ឋ
ប្រធាន
ហត្ថលេខា និង ត្រា: ហេង សំរិន

កន្លែងទទួល:

- ខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណៈបក្សប្រជាជនកម្ពុជា
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
- គ្រប់ទីស្តីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ប្រហាក់ប្រហែល
- គ្រប់គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង
- រដ្ឋកិច្ច
- កាលប្បវត្តិ-ឯកសារ

ដើម្បីចម្លងចែក
អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ
ហត្ថលេខា និង ត្រា: ចាន់ វ៉ែន

លេខ: ៥៣ ច.ល
បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី១៩ ខែ ឧសភា ឆាំ ១៩៩២
អនុប្រធានមន្ទីរក្រសួងយុត្តិធម៌
តុង ពាវ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់
## ស្តីពី
## វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី
## បទបញ្ញត្តិទូទៅ

**មាត្រា១-** ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលណាមួយ ជាសង្ហារិម ឬអសង្ហារិម ជារូបី ឬអរូបី ត្រូវទុកជាវត្ថុដាក់បញ្ចាំនឹងម្ចាស់បំណុលទាំងឡាយរបស់ខ្លួន ។ ដូច្នេះវត្ថុទាំងនេះអាចត្រូវរឹបអូសបាន ដើម្បីលក់យកថ្លៃសងម្ចាស់បំណុលទាំងឡាយ ។

ក៏ប៉ុន្តែមិនអាចត្រូវរឹបអូសបានទេ នូវទ្រព្យសម្បត្តិជាសង្ហារិមដូចតទៅ :

១. ប្រដាប់សំរាប់ដំណេកជាចាំបាច់របស់អ្នកត្រូវរឹបអូស និងរបស់គ្រួសារនៃអ្នកនេះដែលរស់នៅជាធម្មតាជាមួយគ្នា ។

២. តុ ទូ និងប្រដាប់ស្លៀកពាក់ខានមិនបានរបស់អ្នកដែលត្រូវរឹបអូស និងរបស់គ្រួសារនៃអ្នកនេះដែលរស់នៅជាធម្មតាជាមួយគ្នា ។

៣. ហត្ថូបករណ៏ និងឧបករណ៍ជាចាំបាច់ដល់ការងារ ឬកិច្ចការខាងវិជ្ជាជីវនៃអ្នកស្រែចំការនិងសិប្បករ ។

៤. គ្រឿងបរិភោគជាចាំបាច់ដល់ឧបភោគបរិភោគរបស់អ្នកត្រូវរឹបអូស និងរបស់គ្រួសារនៃអ្នកនេះដែលរស់នៅជាធម្មតាជាមួយគ្នាក្នុងអំឡុង៣ខែ ។

៥. ប្រដាប់ប្រើប្រាស់ជាចាំបាច់ ប្រចាំថ្ងៃនៃគ្រួសារ ។

៦. វត្ថុទាំងឡាយសំរាប់វិធីក្នុងសាសនា ។

**មាត្រា២-** បៀវត្សប្រាក់ឈ្នួល នៃអ្នករដ្ឋការ និងនិយោជិក ប្រាក់ឈ្នួលរបស់ជនអ្នកបំរើ និងរបស់កម្មករព្រមទាំងលាភការតាមកាលជាអ្វីក៏ដោយ នោះនឹងត្រូវរឹបអូសបាន តែក្នុងសមាមាត្រ ដូចអង្គុលខាងក្រោមនេះលាភការទាំងនេះ ត្រូវគិតដោយយកមូលដ្ឋានរាល់ខែដែលជាគោលគឺ :

១. ផ្នែកតិចជាង ឬស្មើនឹងប្រាំពាន់រៀល " ៥ ០០០ រៀល " នោះពុំអាចរឹបអូសបានទេក្នុងគ្រប់ករណីទាំងអស់ ។

២. ក្នុងខ្ទង់ពីប្រាំពាន់មួយរៀល "៥ ០០១ រៀល" ទៅមួយម៉ឺនប្រាំពាន់រៀល" ១៥ ០០០ រៀល "នោះត្រូវរឹបអូសបានតែមួយភាគប្រាំ " ១/៥ " ប៉ុណ្ណោះទេ ។

៣. ក្នុងខ្ទង់មួយម៉ឺនប្រាំពាន់មួយរៀល " ១៥ ០០១ រៀល " ទៅប្រាំម៉ឺនរៀល " ៥០ ០០០ រៀល" នោះត្រូវរឹបអូសតែពីភាគប្រាំ " ២/៥ " ប៉ុណ្ណោះទេ ។

៤. ក្នុងខ្ទង់ប្រាំម៉ឺនមួយរៀល " ៥០ ០០១ រៀល " ទៅដល់មួយម៉ឺនរៀល " ១០០ ០០០ រៀល " នោះត្រូវរឹបអូសបានពាក់កណ្ដាល ។

៥. ក្នុងខ្ទង់ពីដប់ម៉ឺនមួយរៀល " ១០០ ០០១ រៀល " ទៅដប់ប្រាំមួយម៉ឺនរៀល " ១៦០ ០០០ រៀល " នោះត្រូវរឹបអូសបានតែពីភាគបី " ២/៣ " ប៉ុណ្ណោះទេ ។

៦. ចំនួនលើសពីដប់ប្រាំមួយម៉ឺនរៀល " ១៦០ ០០០ រៀល " ឡើងទៅនោះត្រូវរឹបអូសបានបីភាគបួន " ៣/៤ " ។

**មាត្រា៣ -** ឥណទេយ្យឯកសិទ្ធិ និងឥណទេយ្យមានលក្ខណៈខាងអាហារនោះ អាចរឹបអូសបានមួយភាគប្រាំ " ១/៥ " បន្ថែមលើប្រតិលាភនៃការងារ ដូចមានកំណត់នៅខាងលើស្រាប់ គិតពីខ្ទង់ ប្រាំពាន់មួយរៀល " ៥ ០០១ រៀល " ឡើងទៅ ។

## ជំពូកទី១

## អំពីការរឹបអូស ចលនវត្ថុ

## ផ្នែកទី១

## អំពីរបៀបរឹបអូសចលនវត្ថុ

**មាត្រា៤ -** ម្ចាស់បំណុល នឹងប្ដឹងឱ្យរឹបអូសយកវត្ថុរបស់កូនបំណុល លុះត្រាតែខ្លួនមានសាលក្រម ហើយសាលក្រមនេះមានដាក់រូបមន្តបង្គាប់ឱ្យស្រាប់ ។

**មាត្រា៥ -** បើសេចក្ដីសំរេចពីតុលាការមានដាក់សេចក្ដីឱ្យសំរេចតាមនោះ មានអនុញ្ញាតិឱ្យកូនបំណុលរកប្រាក់សងក្នុងរយះពេលជាកំណត់ ប៉ុណ្ណេះប៉ុណ្ណោះ នោះម្ចាស់បំណុលនឹងប្ដឹងឱ្យរឹបអូសបាន លុះត្រាតែថ្ងៃកំណត់ដែលអនុញ្ញាតិឱ្យសងនោះផុតទៅហើយ ។

**មាត្រា៦ -** ប៉ុន្តែក្នុងរយះពេលដែលរង់ចាំឱ្យផុតថ្ងៃកំណត់នោះ បើម្ចាស់បំណុលមានហេតុបណ្ដាលឱ្យសង្ស័យក្រែងរបស់ទ្រព្យដែលទុកជាធានានោះក្រែងនឹងបាត់ខ្លះ ឬទាំងអស់ នោះម្ចាស់បំណុលអាចនឹងប្ដឹងដល់ប្រធានតុលាការសុំឱ្យបង្គាប់ឱ្យចាត់ការបង្ការជាបណ្ដោះអាសន្នសិន ដើម្បីឱ្យគង់រូបនៃរបស់ទ្រព្យជាធានានោះបាន ។

**មាត្រា៧ -** ម្ចាស់បំណុលនឹងប្ដឹងសុំឱ្យចាត់ការបង្ការដូចខាងលើនេះបាន ទំរាំពេលណាខ្លួនបានសាលក្រមពីតុលាការជាស្រេចដាច់ខាត ប្រសិនបើបំណុលនោះមានចំនួនជាប្រាកដ ហើយដល់កំណត់ដែលត្រូវសងនោះផង ។

**មាត្រា៨ -** ប្រធានតុលាការត្រូវបង្គាប់ឱ្យចាត់ការបង្ការជាបណ្ដោះអាសន្នសិន បើយល់ឃើញថាត្រូវការបង្គាប់ឱ្យបង្ការនេះ ហើយត្រូវដាក់សេចក្ដីតំរូវតាមត្រូវការ ដើម្បីនឹងឱ្យសំរេចការនោះ ។

**មាត្រា៩ -** ម្ចាស់បំណុល ដើម្បីឱ្យប្រធានតុលាការចាត់វិធានការដូចខាងលើនេះបាន ត្រូវឱ្យមានពាក្យបណ្ដឹងតំកល់នៅការិយាល័យក្រឡាបញ្ជីមុនសិន ទើបតុលាការអាចចេញសាលក្រមយកទៅសំរេចបាន ។

**មាត្រា១០ -** ក្នុងរឿងក្ដីអំពីបំណុល និងអំពីចលនវត្ថុ អាចចេញតែសំរង់សាលក្រមដែលមានដាក់រូបមន្តបង្គាប់ឱ្យសំរេចក៏ជាការគ្រប់គ្រាន់ និងឱ្យចាត់ការសំរេចតាមផ្លូវច្បាប់បានហើយ តែបើក្នុងរឿងក្ដីឯទៀតវិញ មានរឿងក្ដីអំពីអចលនវត្ថុជាដើម ត្រូវតែចេញសេចក្ដីចំលងសាលក្រមទាំងមូល ហើយមានដាក់រូបមន្តបង្គាប់ឱ្យសំរេចតាមផងទើបយកទៅសំរេចតាមផ្លូវច្បាប់បាន ។

**មាត្រា១១ -** ដើម្បីអនុវត្តការដាក់គុកបង្ខំដល់រូបកាយ ក៏ត្រូវចេញសេចក្ដីចំលងសាលក្រមទាំងមូលដែរទើបយកទៅសំរេចបាន ។

**មាត្រា១២ -** ការរឹបអូសចលនវត្ថុ ជាកិច្ចដែលម្ចាស់បំណុលប្ដឹងយកចលនវត្ថុមានរូប របស់កូនបំណុលមកដាក់នៅដៃតុលាការដើម្បីលក់ចលនវត្ថុទាំងនេះ យកថ្លៃលក់នោះសងប្រាក់ជំពាក់ ។

**មាត្រា១៣ -** ការរឹបអូសនេះធ្វើបាននៅគ្រប់ទីកន្លែង ដែលឃើញចលនវត្ថុរបស់កូនបំណុល គឺទោះឃើញនៅនឹងទីលំនៅរបស់កូនបំណុលក៏ដោយ នៅគេហដ្ឋានបណ្ដោះអាសន្នរបស់កូនបំណុលក៏ដោយ នៅផ្លូវថ្នាលជាសាធារណៈក៏ដោយ ។

**មាត្រា១៤ -** របៀបរឹបអូសនេះមានទំរង់ការប្រាំយ៉ាង :

១. យកសំរង់សាលក្រមទៅឱ្យដំណឹងដល់កូនបំណុល និងមានបង្គាប់ឱ្យសងផង ឬគ្មានបង្គាប់ឱ្យសង ។

២. បង្គាប់ឱ្យសង ។

៣. កំណត់ហេតុអំពីការរឹបអូស ហើយនឹងចាត់ជនម្នាក់ឱ្យរក្សារបស់នេះ ។

៤. បិទប្រកាសឱ្យដំណឹង ។

៥. ពិនិត្យមើលជាថ្មីទៀត ឱ្យដឹងថាវត្ថុដែលរឹបអូសនោះ នៅគ្រប់ដូចមានកត់ក្នុងបញ្ជីឬទេ ហើយនឹងការលក់វត្ថុនោះ ។

**មាត្រា១៥-** ការរឹបអូសចលនវត្ថុនឹងធ្វើបាន លុះត្រាតែបានឱ្យដំណឹងដល់កូនបំណុលរួចស្រេចជាមុនអំពីលិខិតសំរេចចេញរបស់តុលាការដែលត្រូវតែមាន ទើបរឹបអូសបាន ។

**មាត្រា១៦-** ការឱ្យដំណឹង គឺត្រូវប្រគល់លិខិតចំលងសេចក្តីសំរេចរបស់តុលាការ ដែលមានដាក់រូបមន្តបង្គាប់ឱ្យសំរេចតាម ទៅឱ្យកូនបំណុលផ្ទាល់ខ្លួន ឬក៏បិទនៅទីលំនៅ ។ ការប្រគល់នោះត្រូវអ្នកអនុវត្តសាលក្រមជាអ្នកប្រគល់ឱ្យ ហើយបង្គាប់ឱ្យសង ថាបើមិនសងទេនឹងរឹបអូសចលនវត្ថុ ឬដាក់គុកបង្ខំដល់រូបកាយ ។

**មាត្រា១៧-** បើបានដំណឹងអំពីសាលក្រមរួចស្រេចហើយ អ្នកអនុវត្តសាលក្រមមិនចំបាច់ឱ្យដំណឹងជាថ្មីទៀតឡើយ ប៉ុន្តែមុននឹងចាត់ការរឹបអូស ត្រូវបង្គាប់ឱ្យកូនបំណុលសងក្នុងរយះពេលជាកំណត់ប៉ុណ្ណេះប៉ុណ្ណោះ ដែលអ្នកអនុវត្តសាលក្រមត្រូវកំរិតដោយខ្លួនឯង ។

**មាត្រា១៨-** សេចក្តីបង្គាប់ឱ្យសងនោះ នឹងទៅជាអសាឥតការ កាលបើកន្លងហួសពី ៣០ថ្ងៃ ហើយអ្នកអនុវត្តសាលក្រមឥតមានចាត់ការរឹបអូសអ្វីសោះឡើយ ។

**មាត្រា១៩-** សេចក្តីបង្គាប់ត្រូវមាន :

១. សេចក្តីឱ្យដំណឹងពីលិខិតសំរេចក្តីរបស់តុលាការដែលត្រូវមាន ទើបចាត់ការរឹបអូសបាន ហើយបើបានឱ្យដំណឹងពីលិខិតសំរេចពីតុលាការនោះរួចហើយ នោះគ្រាន់តែរំលឹកពីសេចក្តីនៃសាលក្រមនោះវិញឡើយ ហើយប្រាប់ចំនួនទឹកប្រាក់ដែលត្រូវសងនោះផង ។

២. បង្គាប់ឱ្យសងប្រាក់នេះ ហើយបើមិនសងទេ នឹងសំរេចតាមផ្លូវច្បាប់ នៅក្នុងរយះពេលមួយជាកំណត់ដែលត្រូវឱ្យកំរិត ។

**មាត្រា២០-** ប្រសិនបើម្ចាស់បំណុល ផ្ទេរឥណទេយ្យនោះឱ្យទៅជនដទៃ ជនដែលទទួលឥណទេយ្យនោះត្រូវឱ្យដំណឹងដល់កូនបំណុលថែមទៀត អំពីសេចក្តីផ្ទេរឥណទេយ្យនេះឱ្យមកខ្លួន ។

បើអ្នកប្តឹងឱ្យរឹបអូសនោះជាអ្នកទទួលមតិក ឬជាអ្នកទទួលអំណោយដោយបណ្តាំខ្មោចនោះ អ្នកទទួលមតិកត្រូវឱ្យដំណឹងពីសំបុត្រមរណៈភាពនៃម្ចាស់មតិកនោះព្រមទាំងកំណត់រាយសាវតាគោត្រកូលរបស់ខ្លួន បើជាអ្នកទទួលអំណោយដោយបណ្តាំខ្មោចវិញ ត្រូវឱ្យដំណឹងសំបុត្របណ្តាំខ្មោចដែលបញ្ជាក់ពីសាវតាខ្លួនជាអ្នកទទួលអំណោយនោះ ។

**មាត្រា២១-** សេចក្តីឱ្យដំណឹងខាងនេះ នឹងឱ្យដំណឹងព្រមជាមួយនឹងសាលក្រមតែម្តងក៏បាន ។

**មាត្រា២២-** បើកូនបំណុលជាអនីតិជន ឬជាអសមត្ថជន ការរឹបអូសត្រូវអនុវត្តទៅលើអ្នកតំណាងពេញច្បាប់ ។

**មាត្រា២៣ -** បើសាលក្រមរបស់តុលាការត្រូវឱ្យកូនបំណុលដទៃទៀតសំរេចតាម ជាជំនួយកូនបំណុលផ្ទាល់ខ្លួនវិញ នោះអ្នកប្តឹងឱ្យរឹបអូសត្រូវឱ្យដំណឹងដល់កូនបំណុលដទៃនោះអំពីសាលក្រម ដែលមានដាក់រូបមន្តបង្គាប់ឱ្យសំរេចតាមនោះ ។

**មាត្រា២៤ -** បើសេចក្តីបង្គាប់ឱ្យសងនោះបានធ្វើមួយដងពីរដងហើយ នៅតែមិនបានជាការទៀតទេ អ្នកអនុវត្តសាលក្រមត្រូវធ្វើកំណត់ហេតុ ។

**មាត្រា២៥ -** នៅក្នុងកំណត់ហេតុនេះ អ្នកអនុវត្តសាលក្រមត្រូវដាក់សេចក្តីថា ត្រូវរឹបអូសទ្រព្យចលនវត្ថុទាំងប៉ុន្មានដែលរឹបអូស ហើយដែលជារបស់កូនបំណុលនោះ ។

**មាត្រា២៦ -** ចាប់តាំងពីពេលនោះតទៅទ្រព្យទាំងនោះ ត្រូវនៅក្នុងដៃតុលាការ ហើយបើជនណាផ្លាស់ប្តូរក្លែងបន្លំ ឬតែបំបាត់យកទ្រព្យនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ខែ ដល់ ៧ឆ្នាំ ។

**មាត្រា២៧ -** នៅក្នុងកំណត់ហេតុនេះ ត្រូវកត់ហេតុការណ៍ទាំងប៉ុន្មានដែលកើតឡើងនៅក្នុងវេលាចាត់ការរឹបអូសឱ្យបានត្រូវពិតប្រាកដ ហើយជាអាទិកត់ត្រាឈ្មោះនិងចំនួនទ្រព្យដែលរឹបអូសនោះឱ្យបានពិស្តារ ។

**មាត្រា២៨ -** បើពុំកត់ត្រាឈ្មោះនឹងចំនួនទ្រព្យទាំងនោះឱ្យពិស្តារទេ ត្រូវទុកជាអសាឥតបានការ ។

**មាត្រា២៩ -** បើរបស់ទ្រព្យដែលរឹបអូសនោះមានបែបភាពដូចគ្នា ហើយមានតំលៃក៏បន្តិចបន្តួច នោះនឹងប្រមូលតែមួយដីរឹបអូសក៏បាន ។

**មាត្រា៣០ -** ទំនិញទាំងឡាយ ឬតាមគោលការណ៍វត្ថុណាដែលចូលក្នុងជំនួញបាននោះត្រូវរឹបអូសក៏បាន ប៉ុន្តែទំនិញទាំងនោះត្រូវតែថ្លឹងវាស់ ឬវាស់តាមបែបភាពឱ្យដឹងចំនួន ។

**មាត្រា៣១ -** លោហៈធាតុមានតំលៃ ត្បូងថ្មមានតំលៃ និងគង់តែរឹបអូសត្រូវវាយឈ្មោះ និងបែបភាពឱ្យប្រគល់រូប ហើយឱ្យកត់ទាំងត្រាដែលបោះក្នុងវត្ថុនោះផងបើមានត្រា ។ ប្រសិនបើត្រានោះរលប់អស់ទៅ ត្រូវឱ្យកត់បញ្ជាក់ដូច្នេះនៅក្នុងកំណត់ហេតុផង គ្រឿងប្រាក់ក៏ត្រូវថ្លឹងដែរ ។

**មាត្រា៣២ -** បើប្រសិនជាប្រាក់ចាយត្រូវឱ្យកត់នៅក្នុងកំណត់ហេតុពីចំនួនទឹកប្រាក់ និងប្រភេទនៃប្រាក់ចាយនោះ ។ អ្នកអនុវត្តសាលក្រមអាចយកប្រាក់ចាយនោះទៅទុកនៅមន្ទីរបស់ខ្លួន ឬទុកនៅកន្លែងណាមួយដែលខ្លួនយល់ថាអាចធានាបាន ។

**មាត្រា៣៣ -** ប៉ុន្តែអ្នកអនុវត្តសាលក្រមត្រូវទុកឱ្យជន ដែលត្រូវរឹបអូសនូវប្រាក់មួយចំនួនល្មមនឹងទិញស្បៀងអាហារចិញ្ចឹមជីវិត និងក្រុមគ្រួសាររបស់ខ្លួនបានក្នុងកំណត់ ៣ខែ ។

**មាត្រា៣៤ -** អ្នកអនុវត្តសាលក្រមមិនត្រូវឆែកឆេរលើខ្លួនកូនបំណុល ឬ ជនដែលនៅស៊ីឈ្នួលបំរើកូនបំណុលនោះទេ ប៉ុន្តែបើកូនបំណុលមានពាក់គ្រឿងប្រាក់ មាស ឬ គ្រឿងអ្វីមួយមានតម្លៃ នោះអ្នកអនុវត្តសាលក្រមអាចរឹបអូសគ្រឿងនេះបានលើកលែងតែគ្រឿងប្រដាប់ដែលពាក់បង្ការសត្រូវដែលគេហៅថាគាថានោះមិនត្រូវរឹបអូសឡើយ ។

**មាត្រា៣៥ -** ក្នុងការរឹបអូសនេះអ្នកអនុវត្តសាលក្រមត្រូវមានសាក្សីពីរនាក់អមផង ។ ឯសាក្សីនេះហៅថាសាក្សីខាងអ្នកអនុវត្តសាលក្រម ។ សាក្សីនេះត្រូវតែជានីតិជន ហើយមិនអោយជាប់ជាញាតិ ឬ ញាតិពន្ធនិងគូក្តី ឬនិងអ្នកអនុវត្តសាលក្រមរហូតសល់ជីដូនមួយបង្កើត រាប់ទាំងថ្នាក់នេះផងនិងមិនឱ្យត្រូវជាឈ្នួលនៃគូក្តី ឬ អ្នកអនុវត្តសាលក្រមឡើយ ។

**មាត្រា៣៦ -** បើគ្មានសាក្សីដូច្នេះទេ ត្រូវទុកការរឹបអូសចលនវត្ថុជាអសាឥតបានការ ។

**មាត្រា៣៧ -** កាលបើអ្នកអនុវត្តសាលក្រមដែលទៅចាត់ការរឹបអូស ឃើញផ្ទះកូនបំណុលបិទទ្វារទាំងអស់នោះអ្នកអនុវត្តសាលក្រមត្រូវរកជនម្នាក់មកចាំផ្ទះនេះ ដើម្បីកុំឱ្យជនណាមកលបតែបំបាត់យកវត្ថុអ្វីបាន ហើយអ្នកអនុវត្តសាលក្រមត្រូវទៅរកប្រធាន ឬអនុប្រធានគណៈកម្មាធិការឃុំ ឬសង្កាត់ឱ្យមកមើល រួចឱ្យជាងម្នាក់ ឬអ្នកស្រុកម្នាក់បើកទ្វារផ្ទះនោះនៅចំពោះមុខប្រធាន ឬអនុប្រធានគណៈកម្មាធិការឃុំ ឬសង្កាត់នោះ ឯចលនវត្ថុនានាឯទៀត ដែលបិទក៏ត្រូវឱ្យបើក ហើយកត់ត្រារឹបអូសបន្តៗ គ្នាទៅនៅពេលវេលានោះ ។

ឯប្រធាន ឬអនុប្រធានគណៈកម្មាធិការឃុំ ឬសង្កាត់ត្រូវឱ្យចុះហត្ថលេខានៅលើកំណត់ហេតុ ដែលអ្នកអនុវត្តសាលក្រមបានធ្វើអំពីការរឹបអូសនោះផងដែរ ។

**មាត្រា៣៨ -** បើជនដែលត្រូវរឹបអូសនោះនៅផ្ទះ ហើយបើទ្វារផ្ទះនោះបើករួចដោយសំរួល ឬដោយបង្ខំអ្នកអនុវត្តសាលក្រមត្រូវបង្គាប់កូនបំណុលនោះថែមទៀតថា ត្រូវឱ្យសងប្រាក់ជំពាក់នៅទីកន្លែងនេះឱ្យហើយទៅ ។ ឯសេចក្តីបង្គាប់នេះត្រូវឱ្យដាក់នៅក្នុងកំណត់ហេតុដែលត្រូវធ្វើតាមមាត្រា ២៥ នៃច្បាប់នេះ ។ ប៉ុន្តែបើមិនធ្វើតាមរបៀបនេះក៏មិនត្រូវឱ្យទុកកំណត់ហេតុជាអសាឥតការឡើយ ។

**មាត្រា៣៩ -** អ្នកអនុវត្តសាលក្រមត្រូវឱ្យបើកគ្រប់បន្ទប់ និងគ្រប់ទូ តុ រហូតដល់បន្ទប់ដែលជួលទៅឱ្យគេនៅនោះផង ។ បើអ្នកជួលប្រកែកពុំព្រមឱ្យបើក អ្នកអនុវត្តសាលក្រមត្រូវចាត់ការដូចមានបញ្ញត្តិនៅមាត្រា ៣៧ នៃច្បាប់នេះ ។

កំណត់ហេតុនេះ ត្រូវឱ្យមានកត់ថ្ងៃ ខែ ឆ្នាំដែលនឹងត្រូវលក់ឡាយឡុងវត្ថុរឹបអូស នោះផង ប៉ុន្តែបើមិនកត់ដូច្នេះទេក៏មិនត្រូវទុកកំណត់ហេតុនោះជាអសាឥតការឡើយ ។

**មាត្រា៩០ -** អ្នកអនុសាលក្រមត្រូវរើសរកជនម្នាក់ឱ្យធ្វើជាអ្នករក្សាវត្ថុដែលរឹបអូសនេះ ។ មុខងារអ្នករក្សានេះ គឺត្រូវគ្រប់គ្រងថែរក្សារបស់នោះឱ្យគង់ ប្រយ័ត្នកុំឱ្យជនដែលត្រូវរឹបអូស ឬជនដទៃផ្សេងមកលបតែបំបាត់យកវត្ថុដែលរឹបអូសនោះទៅបាន ឬមកលបយកវត្ថុមានតំលៃច្រើនហើយយកវត្ថុមានតំលៃតិចមកដាក់ជំនួសវិញបានឡើយ ។

**មាត្រា៩១ -** បើជនដែលត្រូវរឹបអូសរកអ្នករក្សាម្នាក់ដែលជាអ្នកមានធនធានគ្រប់គ្រាន់មកឱ្យរក្សារបស់នោះបាន ហើយជននោះក៏ស្ម័គ្រចិត្តធ្វើជាអ្នករក្សារបស់នោះផង នោះអ្នកអនុវត្តសាលក្រមអាចទទួលយកតាមពាក្យសុំបាន ។

**មាត្រា៩២ -** បើនឹងយកជនដែលត្រូវរឹបអូស ឬញាតិពន្ធត្រឹមថ្នាក់ជីដូនមួយបង្កើតមកធ្វើជាអ្នករក្សាក៏បានឱ្យតែម្ចាស់បំណុលយល់ព្រមផងទើបបាន ។ ឯការយល់ព្រមនោះអាចទទួលតែមាត់ទទេក៏បានដែរ ។

**មាត្រា៩៣ -** បើជនដែលត្រូវរឹបអូសមានវត្ថុមាននៅនឹងផ្ទះនោះអាចនឹងយកជននោះឱ្យធ្វើជាអ្នករក្សាបានទោះបីម្ចាស់បំណុលមិនព្រមក៏ដោយ បើឃើញថាវត្ថុដែលរឹបអូសនោះមានតំលៃតិចជាងសោហ៊ុយដែលត្រូវចំណាយឱ្យអ្នករក្សាម្នាក់ទៀត ។

**មាត្រា៩៤ -** កំណត់ហេតុនោះតាមគោលការណ៍ត្រូវធ្វើនៅទីកន្លែងដែលរឹបអូស ហើយត្រូវឱ្យអ្នករក្សាចុះហត្ថលេខា ឬផ្តិតមេដៃ ។ បន្ទាប់មកត្រូវប្រគល់សេចក្តីកំណត់ហេតុនេះទៅឱ្យអ្នករក្សាមួយច្បាប់ ។ សេចក្តីចំលងកំណត់ហេតុនេះ ត្រូវឱ្យមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកអនុវត្តសាលក្រម សាក្សី និងអ្នករក្សាផង ។

**មាត្រា៩៥ -** បើការរឹបអូសនេះ ធ្វើនៅផ្ទះជនដែលត្រូវរឹបអូស ហើយនៅចំពោះមុខជននេះផង អ្នកអនុវត្តសាលក្រមត្រូវប្រគល់សេចក្តីចំលងកំណត់ហេតុឱ្យជននេះមួយច្បាប់ ដើម្បីជៀសវាងកុំឱ្យមានការទាស់ទែងគ្នាអំពីការផ្លាស់ប្តូរក្លែងបន្លំ តែបំបាត់វត្ថុដែលរឹបអូសតទៅថ្ងៃមុខ ។

**មាត្រា៩៦ -** បើជនដែលត្រូវរឹបអូសមិននៅ អ្នកអនុវត្តសាលក្រមត្រូវប្រគល់សេចក្តីចំលងកំណត់ហេតុមួយច្បាប់ទៅឱ្យប្រធាន ឬអនុប្រធានគណៈកម្មាធិការឃុំ ឬសង្កាត់ ឯប្រធាន ឬអនុប្រធានគណៈកម្មាធិការឃុំ ឬសង្កាត់នេះត្រូវចុះសេចក្តីថា បានឃើញនៅដើមកំណត់ហេតុនេះផង ។ ប្រធាន ឬអនុប្រធានគណៈកម្មាធិការឃុំ ឬសង្កាត់ប្រគល់សេចក្តីចំលងនេះឱ្យជនដែលរឹបអូសនោះ កាលណាជននេះចូលមកផ្ទះវិញ ។

**មាត្រា៩៧ -** បើការរឹបអូសនេះត្រូវធ្វើនៅទីកន្លែងក្រៅពីផ្ទះជនដែលត្រូវរឹបអូស ហើយជននោះមិននៅផង អ្នកអនុវត្តសាលក្រមត្រូវប្តឹងដល់ប្រធានតុលាការសុំឱ្យចេញដីការមួយច្បាប់អំពីរឿងនេះ ។

**មាត្រា៤៨-** ហាមមិនឱ្យអ្នករក្សា ប្រើប្រាស់វត្ថុដែលរឹបអូស ជួល ឬឱ្យគេខ្ចីឡើយ អ្នករក្សាត្រូវថែរក្សាវត្ថុដែលរឹបអូសនេះបីដូចជាខ្លួនជាម្ចាស់របស់ ។

បើអ្នករក្សាធ្វើល្មើសនឹងបញ្ញត្តិនេះ និងត្រូវទទួលសងជំងឺចិត្ត ហើយការរក្សាវត្ថុក៏ត្រូវដកពីអ្នករក្សានោះចេញវិញ ។

**មាត្រា៤៩-** ឈ្នួលរក្សាវត្ថុនេះត្រូវគិតមួយពាន់ប្រាំរយរៀល " ១ ៥០០ រៀល " ក្នុងមួយថ្ងៃជាអតិបរមា ។

**មាត្រា៥០-** អ្នកអនុវត្តសាលក្រមត្រូវកំណត់តំលៃនៃវត្ថុនីមួយៗ ដែលត្រូវរឹបអូសតាមតំលៃប៉ាន់ស្មានតំលៃនេះត្រូវចុះក្នុងកំណត់ហេតុឱ្យចំមុខទាំងនោះ ។

**មាត្រា៥១-** បើចលនវត្ថុដែលវាយតំលៃមិនលើសពី ១៥ ០០០ រៀល អ្នកអនុវត្តសាលក្រមត្រូវធ្វើកំណត់ហេតុបញ្ជាក់ថារបស់នេះតិចពេក មិនធួននឹងសងបំណុល ហើយមិនត្រូវឱ្យរឹបអូសទេ ។

នៅក្នុងកំណត់ហេតុនេះ អ្នកអនុវត្តសាលក្រមត្រូវដាក់សេចក្តីថាមានចលនវត្ថុមិនគ្រប់គ្រាន់ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅការិយាល័យក្រឡាបញ្ជី ដើម្បីដាក់ក្នុងសំណុំរឿង ។

**មាត្រា៥២-** អ្នកអនុវត្តសាលក្រម កាលបើបានធ្វើបញ្ជីកាត់តំលៃចលនវត្ថុនេះហើយ ត្រូវដាក់នៅក្នុងកំណត់ហេតុនោះផង ថ្ងៃ ខែ ឆ្នាំ ដែលនឹងត្រូវលក់ឡាយឡុងចលនវត្ថុនោះ ។

**មាត្រា៥៣-** អ្នកអនុវត្តសាលក្រមត្រូវយកសេចក្តីចំលងកំណត់ហេតុនេះមួយច្បាប់ទៅបិទភ្លាមមួយរំពេចនៅទីស្នាក់ការគណៈកម្មាធិការឃុំ ឬសង្កាត់ និងនៅទីលំនៅនៃកូនបំណុលដែលត្រូវរឹបអូស ។ កិច្ចទាំងពីខាងលើនេះបើមិនធ្វើតាមទេ និងត្រូវទុកកិច្ចការដែលធ្វើនេះជាអសាឥតបានការហើយនឹងចាត់តាំងការតទៅទៀតបានឡើយ ។

**មាត្រា៥៤-** ការលក់ឡាយឡុងនឹងត្រូវលក់ក្នុងកំណត់ ៣០ ថ្ងៃគត់យ៉ាងយូរ គិតតាំងពីថ្ងៃដែលធ្វើបញ្ជីកាត់តំលៃចលនវត្ថុតាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់នេះ ។

**មាត្រា៥៥-** នៅថ្ងៃលក់ឡាយឡុង អ្នកអនុវត្តសាលក្រមត្រូវពិនិត្យរាប់មើលវត្ថុដែលរឹបអូស គឺត្រូវពិនិត្យមើលវត្ថុនេះតាមបញ្ជីឱ្យដឹងក្រែងមានវត្ថុឯណាមួយ ឬច្រើនបាត់រូប ។

**មាត្រា៥៦-** បើអ្នកអនុវត្តសាលក្រមពិនិត្យទៅឃើញមានបាត់វត្ថុដែលរឹបអូស អ្នកអនុវត្តសាលក្រមត្រូវធ្វើអង្កេតភ្លាម ហើយបើអង្កេតទៅឃើញថាមានគេផ្លាស់ប្តូរក្លែងបន្លំ ឬតែបំបាត់នោះត្រូវរកអាជ្ញាធមានសមត្ថកិច្ចឱ្យនាំជនប្រព្រឹត្តិនោះទៅតុលាការ ។

**មាត្រា៥៧-** អ្នកអនុវត្តសាលក្រមត្រូវលក់ឡាយឡុងវត្ថុដែលរឹបអូសតាមលេខរៀង និងតាមថ្ងៃដែលកត់នៅក្នុងបញ្ជី ។

ប៉ុន្តែ បើវត្ថុដែលរឹបអូសនោះមានតំលៃលើសពីប្រាក់ដែលជំពាក់ គិតទាំងចុងការនិងសោហ៊ុយផង នោះកូនបំណុលអាចប្តឹងសុំឱ្យលក់វត្ថុណាខ្លះ មុនវត្ថុឯទៀតបាន ដើម្បីនឹងបានទុកវត្ថុណា ដែលខ្លួនពេញចិត្តជាងគេ ។

**មាត្រា៥៨-** ប្រសិនបើមានចលាចលផ្សេងៗ នៅពេលវេលាដែលកំពុងលក់ឡាយឡុង អ្នកអនុវត្តសាលក្រមត្រូវធ្វើកំណត់ហេតុអំពីរឿងនេះ ហើយត្រូវរកអាជ្ញាធរមានសមត្ថកិច្ចនាំជនប្រព្រឹត្តិបទល្មើសទៅតុលាការ ។

**មាត្រា៥៩-** កាលបើលក់ឡាយឡុងវត្ថុនោះខ្លះទៅហើយបានចំនួនប្រាក់គ្រប់គ្រាន់ ល្មមសងម្ចាស់បំណុលទាំងប្រាក់ដើម ទាំងប្រាក់ការនិងសោហ៊ុយផង ត្រូវឈប់លក់វត្ថុនេះតទៅទៀត ។

**មាត្រា៦០-** ការលក់ឡាយឡុង ត្រូវលក់យកថ្លៃដល់ដៃ គឺថាកាលបើបានប្រគល់វត្ថុនោះឱ្យអ្នកទិញត្រូវចេញថ្លៃឱ្យភ្លាម ។

**មាត្រា៦១-** ប្រាក់ដែលបានមកពីលក់វត្ថុឡាយឡុងនោះ ត្រូវប្រគល់ឱ្យម្ចាស់បំណុល ។ ម្ចាស់បំណុលត្រូវសរសេរនៅក្រោមកំណត់ហេតុលក់ឡាយឡុងថា បានទទួលប្រាក់ ហើយចុះហត្ថលេខានៅខាងក្រោម ។ ឯកំណត់ហេតុនេះត្រូវតែធ្វើភ្លាមៗ ។ បើម្ចាស់បំណុលមិនចេះអក្សរទេ ត្រូវប្រគល់ប្រាក់ឱ្យម្ចាស់បំណុលនៅចំពោះមុខសាក្សីពីរនាក់ ។

**មាត្រា៦២-** បើអ្នកអនុវត្តសាលក្រមប្រគល់ឱ្យម្ចាស់បំណុលភ្លាមមិនបានទេ ព្រោះមានបណ្តឹងប្តឹងទាស់ដូចមានបញ្ញត្តិត្រង់មាត្រា ៧០ និង ៧២ នៃច្បាប់នេះ នោះអនុវត្តសាលក្រមត្រូវយកប្រាក់នេះ ទៅតំកល់ទុកនៅការិយាល័យក្រឡាបញ្ជីក្នុងរវាង ៣ ថ្ងៃយ៉ាងយូរ ។

**មាត្រា៦៣-** បើលក់ឡាយឡុងទៅហើយ គ្មានជនណាមកដេញថ្លៃបានទេ ត្រូវលក់វត្ថុដែលរឹបអូសនោះទៅឱ្យម្ចាស់បំណុលតាមកំរិតថ្លៃដែលកាត់ទុកជាមុន ហើយដែលកត់នៅក្នុងបញ្ជី ដើម្បីសងប្រាក់ជំពាក់ឱ្យរួចទាំងអស់ ឬខ្លះតាមថ្លៃវត្ថុដែលលក់បាន ។

បើថ្លៃលក់វត្ថុនោះយកមកសងប្រាក់ជំពាក់ មិនរួចទាំងអស់នោះទេ ត្រូវឱ្យកូនបំណុលទទួលជំពាក់ប្រាក់ដែលនៅសល់នោះតទៅទៀត ។ បើដូច្នេះអ្នកអនុវត្តសាលក្រមត្រូវកត់ត្រាចំនួនប្រាក់ដែលប្រគល់ឱ្យម្ចាស់បំណុលនៅលើខ្នងលិខិតបំណុលប្រសិនបើមានលិខិតនោះ ។

បើយកប្រាក់លក់វត្ថុនោះមកសងប្រាក់ជំពាក់គ្រប់ចំនួនហើយ អ្នកអនុវត្តសាលក្រមត្រូវប្រគល់សំបុត្រទៅឱ្យកូនបំណុលវិញ ។

**មាត្រា៦៤-** អ្នកអនុវត្តសាលក្រមត្រូវទទួលខុសត្រូវផ្ទាល់ ពីប្រាក់ដែលបានមកពីការលក់ឡាយឡុងវត្ថុនោះ ហើយអ្នកអនុវត្តសាលក្រមមិនត្រូវទទួលប្រាក់លើសពីថ្លៃលក់បានឡើយ បើទទួលប្រាក់លើសពីចំនួននោះនឹងត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ ៧ ខែ ។

## ផ្នែកទី ២

## អំពីឧប្បត្តិហេតុ

**មាត្រា៦៥-** នៅពេលដែលចាត់ការរឹបអូស អាចមានឧប្បត្តិហេតុផ្សេងៗកើតឡើង ព្រោះជួនកាលមានការប្ដឹងទាស់នឹងការរឹបអូសនោះ ។ ការប្ដឹងទាស់ទាំងនោះអាចមានមក :

១. ពីជនដែលត្រូវរឹបអូស

២. ពីម្ចាស់បំណុលនៃជនដែលត្រូវរឹបអូស ក្រៅពីម្ចាស់បំណុលដែលប្ដឹងឱ្យរឹបអូសនោះ

៣. ពីជនដទៃដែលគេតវ៉ាថា ចលនវត្ថុដែលត្រូវរឹបអូសទាំងអស់ ឬខ្លះជារបស់គេ ។

**មាត្រា៦៦-** នៅពេលដែលអ្នកអនុវត្តសាលក្រមកំពុងចាត់ការរឹបអូស ជនដែលត្រូវរឹបអូសអាចនឹងប្ដឹងទាស់បាន ក្នុងករណីនេះអ្នកអនុវត្តសាលក្រមត្រូវធ្វើកំណត់ហេតុភ្លាមមួយរំពេច ដោយចុះសេចក្ដីបណ្ដឹងនោះនៅក្នុងកំណត់ហេតុ ។ បើអ្នកអនុវត្តសាលក្រមយល់ថា បណ្ដឹងទាស់នេះគ្មានសំអាងច្បាស់លាស់ អ្នកអនុវត្តសាលក្រមនឹងចេះតែចាត់ការរឹបអូសនេះតទៅទៀតបាន ។ ប៉ុន្តែនៅក្នុងកំណត់ហេតុនោះត្រូវឱ្យរាយហេតុដែលបណ្ដាលឱ្យធ្វើដូច្នេះ ឯចំណែកជនដែលត្រូវរឹបអូសនោះនៅវេលាដែលអ្នកអនុវត្តសាលក្រមចាត់ការរឹបអូសរួចហើយភ្លាមមានសិទ្ធិប្ដឹងដល់តុលាការ សុំឱ្យចេញដីកាសំរេចឱ្យខ្លួនជាប្រញាប់អំពីបណ្ដឹងទាស់នេះ ។

**មាត្រា៦៧-** បើការប្ដឹងទាស់ពីការរឹបអូសនោះ ប្ដឹងក្រោយពេលដែលអ្នកអនុវត្តសាលក្រមបានធ្វើកំណត់ហេតុពីការរឹបអូសនេះរួច នោះជនដែលត្រូវរឹបអូសត្រូវយកពាក្យប្ដឹងទាស់ទៅជូនប្រធានតុលាការដោយខ្លួនឯង ។ ឯប្រធានតុលាការបើបានទទួលពាក្យប្ដឹងទាស់នោះហើយ ត្រូវចេញដីកាសំរេចពីរឿងនេះភ្លាម ។

**មាត្រា៦៨-** បើការប្ដឹងទាស់នោះធ្វើមុនការរឹបអូស ហើយប្រធានតុលាការពុំបានសំរេចឱ្យទាន់មុនថ្ងៃដែលត្រូវលក់ឡាយឡុងវត្ថុនោះទេ ជនដែលត្រូវរឹបអូសត្រូវជូនបង្កាន់ដៃក្រលាបញ្ជីបញ្ជាក់អំពីការទទួលពាក្យប្ដឹងទាស់នោះទៅអ្នកអនុវត្តសាលក្រម ឯបង្កាន់ដៃនោះត្រូវអ្នកក្រលាបញ្ជីចេញឱ្យជាដរាប ។ ឯអ្នកអនុវត្តសាលក្រមកាលបើទទួលបង្កាន់ដៃនោះ ហើយមិនត្រូវលក់ឡាយឡុងវត្ថុនោះឡើយ បើគ្មានបង្កាន់ដៃអ្វីជូនទៅអ្នកអនុវត្តសាលក្រមទេ នោះអ្នកអនុវត្តសាលក្រមត្រូវតែចាត់ការលក់ឡាយឡុងតទៅ ។

**មាត្រា៦៩-** បើសំរេចថា ត្រូវទុកពាក្យប្ដឹងទាស់ថាបានការហើយ អ្នកអនុវត្តសាលក្រមត្រូវឈប់លក់ឡាយឡុង ។

**មាត្រា៧០ -** ឯម្ចាស់បំនុលនៃជនដែលត្រូវរឹបអូស ទោះដោយប្រការយ៉ាងណាក្តី មិនអាចប្តឹងទាស់មិនឱ្យលក់ឡាយឡុងបានឡើយ ប៉ុន្តែម្ចាស់បំណុលអាចប្តឹងទាស់សុំកុំឱ្យយកប្រាក់ដែលលក់បាននោះ ទៅចែកចាយជាសំណងបាន ។ ក្នុងករណីខាងក្រោមនេះម្ចាស់បំណុលនៃជនដែលត្រូវរឹបអូសនេះ ត្រូវប្តឹងទៅអ្នកអនុវត្តសាលក្រមមុនពេលលក់ឡាយឡុងក៏បាន កំពុងតែលក់ឡាយឡុងក៏បាន ។ អ្នកអនុវត្តសាលក្រមត្រូវកត់បណ្តឹងទាស់នោះក្នុងកំណត់ហេតុលក់ឡាយឡុង ។

បើមានការប្តឹងទាស់ សុំកុំឱ្យយកប្រាក់ដែលលក់បាននោះទៅចែកចាយជាសំណងនោះ អ្នកអនុវត្តសាលក្រមមិនត្រូវប្រគល់ប្រាក់នោះឱ្យទៅម្ចាសបំណុលដែលជាអ្នកសុំឱ្យរឹបអូសនោះឡើយ ។ ប្រាក់នោះអ្នកអនុវត្តសាលក្រមត្រូវយកទៅទុកនៅការិយាល័យក្រលាបញ្ជី ឬទីកន្លែងណាដែលយល់ឃើញថាធានាបាន ហើយក្នុងរវាង ១០ថ្ងៃម្ចាស់បំណុលដែលប្តឹងទាស់ត្រូវជូនពាក្យដល់តុលាការសុំឱ្យសំរេចអំពីបណ្តឹងទាស់នោះ ។

**មាត្រា៧១ -** លុះផុតកំណត់ ១០ ថ្ងៃហើយហើយពុំឃើញម្ចាស់បំណុលដែលប្តឹងទាស់នោះជូនពាក្យដល់តុលាការទេនោះ ម្ចាស់បំណុលដែលជាអ្នកប្តឹងសុំឱ្យរឹបអូស អាចសុំបើកយកប្រាក់ដែលតំកល់នោះបាន ។

**មាត្រា៧២ -** ជនដែលប្រកាន់ថា វត្ថុដែលរឹបអូសទាំងអស់ ឬខ្លះនោះជារបស់ខ្លួន ជននោះអាចប្តឹងទាស់សុំកុំឱ្យលក់ឡាយឡុងបាន ។ បណ្តឹងទាស់នោះនឹងទុកជាត្រឹមត្រូវបាន លុះត្រាតែប្តឹងឱ្យមុនថ្ងៃដែលកំរិតឱ្យលក់ឡាយឡុង ឬ នៅពេលដែលកំពុងលក់ ។

**មាត្រា៧៣ -** ជនណាដែលប្រកាន់ខ្លួនជាម្ចាស់វត្ថុ ត្រូវជូនពាក្យមួយច្បាប់មកអ្នកអនុវត្តសាលក្រម ព្រមជាមួយនិងសំបុត្រស្នាមផ្សេងៗ សំគាល់ខ្លួនជាម្ចាស់វត្ថុនោះបើមាន ឬ ភស្តុតាងអ្វីផ្សេងៗ ទៀតដើម្បីជាសំអាងនៃសេចក្តីតវ៉ាថាខ្លួនជាម្ចាស់វត្ថុនោះ ។

បើអ្នកប្តឹងទាស់នោះមិនចេះសរសេរ ត្រូវអោយប្តឹងទាស់ដល់អ្នកអនុវត្តសាលក្រមតែមាត់ទទេ អ្នកអនុវត្តសាលក្រមត្រូវកត់ចំលើយតាមពាក្យប្តឹងទាស់នោះ ហើយអោយមានសាក្សីពីនាក់បញ្ជាក់ ពីសាវតាជាតិនៃអ្នកប្តឹងទាស់នោះផង ។

**មាត្រា៧៤ -** បើការប្តឹងទាស់នោះទាក់ទងតែនឹងលើរូបវត្ថុខ្លះទេ នោះត្រូវអោយទុកវត្ថុនោះសិនកុំ អាលឱ្យលក់ឡាយឡុង ឯវត្ថុឯទៀតត្រូវអោយលក់ទៅ ។

**មាត្រា៧៥ -** បើពាក់ពន្ធ័ទៅលើរូបវត្ថុទាំងអស់ ឬ លើរូបវត្ថុភាគច្រើន អ្នកអនុវត្តសាលក្រមត្រូវឈប់ឡាយឡុងសិន ។

ពាក្យប្តឹងទាស់ ឬ កំណត់ហេតុដែលកត់ចំលើយប្តឹងទាស់នេះ អ្នកអនុវត្តសាលក្រមត្រូវបញ្ជូនទៅតុលាការដែលត្រូវសំរេចរឿងនេះដោយដីកាជាប្រញាប់ ឯវត្ថុដែលរឹបអូសនឹងលក់ឡាយឡុងនោះ អ្នកអនុវត្តសាលក្រមត្រូវប្រគល់ទៅឱ្យជនដែលទទួលរក្សានោះរក្សាតទៅទៀត រងចាំស្តាប់សេចក្តីសំរេចពីតុលាការ ។

**មាត្រា៧៦ -** បើប្រធានតុលាការចេញដីការសំរេចថាត្រូវតែអោយលក់ឡាយឡុងតទៅ ត្រូវតែសំរេចតាមដីកានោះ ទោះបីអ្នកប្តឹងទាស់ប្តឹងតវ៉ាទៀត ពីប្រធានតុលាការក៏ដោយ ។

**មាត្រា៧៧ -** បើមានហេតុដូច្នេះប្រាក់ដែលបានមកពីការលក់ឡាយឡុងនោះ ត្រូវអ្នកអនុវត្តសាលក្រមយកទៅដំកល់ទុកនៅការិយាល័យក្រលាបញ្ជីតាមបញ្ញត្តិមាត្រា ៦២ នៃច្បាប់នេះ រក្សាទុកទាល់តែពេលណាតុលាការសំរេចពីបណ្តឹងទាស់នោះហើយស្រេច ។

អ្នកប្តឹងទាស់ត្រូវប្តឹងតវ៉ាពីដីកាប្រធានតុលាការក្នុងកំណត់ដប់ថ្ងៃគត់ បើខ្លួនពុំសុខចិត្តនឹងដីកានោះ បើទុកអោយហួសពីកំណត់នោះហើយ ត្រូវទុកដីការបស់ប្រធានតុលាការប្រជាជនជាស្រេចដាច់ខាត់ តទៅ ហើយពុំអាចប្តឹងតវ៉ាអ្វីទៀតបានឡើយ ។

ការប្តឹងតវ៉ារបស់ប្រធានតុលាការប្រជាជននោះ ត្រូវឱ្យមានពាក្យមួយច្បាប់ប្តឹងសូមអោយតុលាការប្រជាជនជំនុំជំនះរឿងនោះ ។ ការប្តឹងដូច្នេះមិនចាំបាច់អោយមានសេចក្តីផ្សះផ្សាពីមុនឡើយ ។

**មាត្រា៧៨ -** កាលពីមានច្បាប់បំណុលឯទៀតប្តឹងមុនថ្ងៃលក់ឡាយឡុងក្តី ឬនៅវេលាកំពុងលក់ឡាយឡុងក្តី ជំទាស់សុំកុំអោយមានការប្រគល់ប្រាក់ដែលបានមកពីម្ចាស់បំណុល ដែលជាអ្នកប្តឹងសុំអោយរឹបអូសដូចមានបញ្ញត្តិក្នុងមាត្រា៧០ នៃច្បាប់នោះក្រលាបញ្ជី ក្រោយពីបានទទួលប្រាក់ពីអ្នកអនុវត្តសាលក្រមនោះក្នុងរយះ១៥ ថ្ងៃត្រូវកោះជនដែលត្រូវរឹបអូស ម្ចាស់បំណុលជាអ្នកប្តឹងសុំអោយរឹបអូស និងម្ចាស់បំណុលជាអ្នកប្តឹងទាស់ ឱ្យចូលមកតុលាការប្រជាជន ហើយប្រជាជនតុលាការ ឬ ចៅក្រមម្នាស់ដែលត្រូវចាត់ពីប្រធានតុលាការយកប្រាក់នោះមកចែកសងឱ្យម្ចាស់បំណុលទាំងនោះតាមសមធម៌នៅក្នុងបន្ទប់របស់ខ្លួន ។

**មាត្រា៧៩ -** បើធ្វើដូច្នេះទៅហើយនៅតែមានការទាស់ទែងពុំព្រមព្រៀងគ្នាទៀត ត្រូវអោយជនដែលប្តឹងទាស់សុំកុំអាលអោយចែកប្រាក់នេះ ឬក៏ម្ចាស់បំណុលដែលជាអ្នកប្តឹងណាមួយ ប្តឹងតវ៉ាទៅតុលាការសូមអោយសំរេច សចក្តីឱ្យ ។

**មាត្រា៨០ -** ការបែងចែកប្រាក់សងបំណុលនេះ ត្រូវអោយធ្វើកំណត់ហេតុមួយច្បាប់ដែលត្រូវអោយគូនក្តីទាំងអស់ចុះហត្ថលេខាផង ឯដើមកំណត់ហេតុនេះត្រូវទុកនៅការិយាល័យក្រលាបញ្ជី ។

**មាត្រា៨១ -** បើជនដែលមានប្រយោជន៍ប្តឹងទាស់ចូលមកប្តឹងក្រោយដែលបានលក់ឡាយឡុងរួចស្រេចទៅហើយជននោះគ្រាន់តែមានអំណាចប្តឹងសុំសោហ៊ុយជម្ងឺចិត្តតែប៉ុណ្ណោះ ។

## ជំពូកទី២

## អំពីការរឹបអូសចលនវត្ថុ

**មាត្រា៨២ -** អ្នកអនុសាលក្រមដែលទទួលភារៈទៅរឹបអូសចលនវត្ថុ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដែលប្តឹងសុំឱ្យរឹបអូសប្រគល់មកឱ្យខ្លួននូវសាលក្រមដែលមានដាក់រូបមន្តឱ្យសំរេចតាមអនុវត្ត ហើយដែលតាមអំណាចសាលក្រមនេះហើយដែលនឹងត្រូវចាត់ការរឹបអូស ។

ប្រសិនបើអចលនវត្ថុនោះជាដីដែលមានចុះនៅក្នុងបញ្ជីសុរិយោដីហើយ ត្រូវឱ្យប្រគល់សេចក្តីចំលងពីបញ្ជីនោះមួយ ច្បាប់ដោយភ្ជាប់មកជាមួយនូវសេចក្តីចំលងផែនទី ទីកន្លែងមានដីនោះ ។

អ្នកអនុវត្តសាលក្រមត្រូវបង្គាប់ឱ្យម្ចាស់បំណុលដែលប្តឹងសុំឱ្យរឹបអូសប្រគល់កិច្ចការបញ្ចាំចលនវត្ថុ មកឱ្យខ្លួនផងដែរ ទោះដីនោះមានសង់ផ្ទះគេហដ្ឋានលើក៏ដោយ គ្មានក៏ដោយ ។

**មាត្រា៨៣ -** អ្នកអនុសាលក្រមកាលបីបានលិខិតអ្វីពីម្ចាស់បំណុល ត្រូវចេញបង្កាន់ដៃឱ្យអ្នកនោះ ថាបានទទួលលិខិតនោះហើយ ។ អ្នកអនុវត្តសាលក្រមអាចរកលិខិតទាំងនោះដោយខ្លួនឯងក៏បាន ក្នុងករណីនោះមិនចាំបាច់ចេញបង្កាន់ដៃអ្វីឡើយ ។

**មាត្រា៨៤ -** ការរឹបអូសចលនវត្ថុ ត្រូវឱ្យតំណឹងពីសាលក្រមដល់កូនបំណុល និងឱ្យបង្កាន់ដៃសងប្រាក់ជំពាក់ជាមុន ដូចមានបញ្ញត្តិនៅមាត្រា ១៦ នៃច្បាប់នោះ ទើបចាត់ការរឹបអូសជាក្រោយបាន ។

**មាត្រា៨៥ -** បើកូនបំណុលពុំធ្វើតាមសេចក្តីប្រកាសបង្គាប់នេះទេ ៣០ ថ្ងៃ យ៉ាងតិចក្រោយថ្ងៃដែលបានបង្គាប់ឱ្យសងប្រាក់ អ្នកអនុវត្តសាលក្រមត្រូវធ្វើកំណត់ហេតុរឹបអូសមួយច្បាប់ កំណត់ហេតុនោះត្រូវឱ្យភ្ជាប់ជាមួយផងនូវបញ្ជីរាយមុខព្រមទាំងទំហំនឹងភាព ហើយនឹងទីកន្លែងនៃចលនវត្ថុដែលរឹបអូសនោះបួន ឬប្រាំច្បាប់តាមតំរូវការ ។

ក្នុងបញ្ជីនោះ ត្រូវឱ្យចុះ :

- នាមនឹងទីលំនៅម្ចាស់បំណុលដែលប្តឹងសុំឱ្យរឹបអូស និងជនដែលត្រូវរឹបអូស
- លិខិតចំលងបញ្ជីដី បើដីនោះមានចុះបញ្ជីសុរិយោដី
- ថ្លៃដីដែលកាត់ដោយអ្នកប្តឹងសុំឱ្យរឹបអូស
- ថ្ងៃ ខែ ឆ្នាំ ពេលម៉ោង និងទីកន្លែងដែលត្រូវលក់ឡាយឡុងនោះ ។

**មាត្រា៨៦ -** បើទំហំដីដែលលក់ឡាយឡុងតិចជាងមួយហិតា ហើយនៅលើចលនវត្ថុគ្មានសង់គេហដ្ឋាន ដែលត្រូវទុកជាចលនវត្ថុពីកំណើតទេ នោះត្រូវឱ្យប្រធាន ឬអនុប្រធានកម្មាធិការប្រជាជនឃុំលក់ឡាយឡុងដី នោះនៅទីស្នាក់ការឃុំ នៅចំមុខអ្នកអនុវត្តសាលក្រម ។ ក្រៅពីករណីនេះត្រូវតែលក់ឡាយឡុងនៅ ទីស្នាក់ការតុលាការ ។

**មាត្រា៨៧ -** អ្នកអនុវត្តសាលក្រមត្រូវយកបញ្ជីរាយមុខចលនវត្ថុ មួយច្បាប់ទៅបិទនៅទីស្នាក់ការ ឃុំ ឬសង្កាត់ ដែលចលនវត្ថុនោះស្ថិតនៅ មួយច្បាប់ទៀតទៅបិទនៅទីដីដែលត្រូវលក់ឡាយឡុង មួយ ច្បាប់ទៀតត្រូវយកទៅបិទនៅទីផ្សារ ។ ប្រសិនបើត្រូវលក់នៅទីស្នាក់ការតុលាការ ត្រូវឱ្យបិទបញ្ជីនេះ មួយច្បាប់នៅទីស្នាក់ការនោះផង ។

**មាត្រា៨៨ -** បញ្ជីរាយមុខចលនវត្ថុនេះមួយច្បាប់ត្រូវដាក់ក្នុងសំណុំរឿង ។ បញ្ជីមួយច្បាប់នេះទុកជាបញ្ជីដើម ហើយត្រូវមានចុះនិទ្ទេសនៅក្នុងបញ្ជីនោះថា អ្នកអនុវត្តសាលក្រមបានបិទបញ្ជីនេះជាប្រកាសនៅទីណាៗផង ។

**មាត្រា៨៩ -** បើចលនវត្ថុមានចុះនៅក្នុងបញ្ជីសុរិយោដី នោះអ្នកអនុវត្តសាលក្រមក្រោយពីពេលបិទប្រកាស ហើយឱ្យត្រូវចំលងកំណត់ហេតុ នៃការរឹបអូសចលនវត្ថុនោះ ក្នុងបញ្ជីព័ន្ធខាងសុរិយោដី តែបើពុំបានដូចនេះទេ ដោយហោចណាស់ក៏ត្រូវចុះចំណារអំពីការរឹបអូសនេះដែរ
ដើម្បីឱ្យតតិយជនទាំងពួងដែលមានប្រាថ្នាចង់ទិញអចលនវត្ថុ នោះបាន ដឹងអំពីរឿងនេះផង ។

បើចលនវត្ថុពុំមានចុះបញ្ជីសុរិយោដីទេ នោះចំណារដូចគ្នានេះ ត្រូវចុះក្នុងបញ្ជីភូមបាល ។

**មាត្រា៩០ -** ក្នុងរវាង ៥ ថ្ងៃ គិតតាំងពីថ្ងៃដែលបានបិទបញ្ជីរាយមុខអចលនវត្ថុជាប្រកាសនោះរួច អ្នកអនុវត្តសាលក្រមត្រូវតំណឹងទៅជនដែលត្រូវរឹបអូស និងទៅម្ចាស់បំណុលដែលបានទទួលបញ្ចាំដីនោះ ហើយដែលមានចុះលិខិតបញ្ចាំនៅក្នុងសៀវភៅបញ្ជីសំរាប់ទទួលចុះបណ្ដឹងអំពីកិច្ចនេះ ឬដែលបានទទួលបញ្ចាំហៅហ៊ីប៉ូតែក ពីការដែលរឹបអូសអចលនវត្ថុនោះ ហើយបង្គាប់ថា ត្រូវឱ្យចូលទៅមើលលក់ឡាយឡុងផង ។

នៅចុងដីកាឱ្យតំណឹងដែលប្រគល់ឱ្យកូនបំណុលដែលត្រូវរឹបអូស និងម្ចាស់បំណុលទាំងឡាយនោះ អ្នកអនុវត្តសាលក្រមត្រូវកត់ពតិមានទាំងឡាយអំពីការលក់ឡាយឡុងនោះ ហើយនឹងបញ្ជីរាយរូបអចលនវត្ថុដែលរឹបអូសនោះផង ។ ឯដើមដីកានោះត្រូវឱ្យទុកក្នុងសំណុំរឿង ឬក៏ត្រូវបញ្ជូនទៅឱ្យក្រលាបញ្ជី ដើម្បីទុកក្នុងសំណុំរឿង បើលក់ឡាយឡុងនៅទីស្នាក់ការតុលាការ ។

**មាត្រា៩១-** ចាប់ពីថ្ងៃដែលសាមីខ្លួនទាំងអស់បានទទួលដំណឹងពីការរឹបអូសរួចហើយ ជនដែលត្រូវរឹបអូស ឬអ្នកជួលអចលនវត្ថុដែលរឹបអូសនោះត្រូវបានចាត់តាំងជាអ្នកថែរក្សាទុកពេញច្បាប់នូវផលានុផល និងឈ្នួលនៃអចលនវត្ថុនោះ ។

**មាត្រា៩២-** បើម្ចាស់បំណុលដែលប្ដឹងសុំឱ្យរឹបអូស ឬជនឯទៀតដែលមានប្រយោជន៍ក្នុងរឿងនោះ ប្ដឹងសុំឱ្យចាត់មនុស្សដទៃទៀតក្រៅពីម្ចាស់បំណុល និងជួលអចលនវត្ថុ ឱ្យធ្វើជាអ្នកថែរក្សា នោះនឹងចាត់តាមពាក្យសុំបាន ។

**មាត្រា៩៣-** នឹងប្ដឹងសុំដូច្នេះបាន លុះត្រាដែលម្ចាស់បំណុលដែលប្ដឹងសុំឱ្យរឹបអូស ឬជនឯទៀតនោះជូនពាក្យមួយច្បាប់ ទៅប្រធានតុលាការ ជានាទីនៃអចលនវត្ថុដែលរឹបអូសបាននោះ ហើយប្រធានតុលាការត្រូវសំរេចរឿងនោះ ដោយដីការកិច្ចការប្រញាប់ ។ ក្នុងករណីនេះអ្នកបណ្ដឹងនឹងជនដែលត្រូវរឹបអូសត្រូវកោះឱ្យចូលមក ឯអ្នកអនុវត្តសាលក្រមត្រូវទទួលធ្វើជាតំណាងក្ដីឯទៀត ។ អ្នកថែក្សារត្រូវរើសយកតែជនដែលមានកេរ្តិ៍ឈ្មោះល្អ ។

**មាត្រា៩៤-** ឯរង្វាន់អ្នកថែរក្សាត្រូវប្រធានតុលាការសំរេចតាមសេចក្ដីសុំពីអ្នករក្សានៅវេលាដែលឈប់ថែរក្សា និងក្រោយដែលប្រធានតុលាការ បានសំរេចយលព្រមពីប្រាក់ចំនូលចំណាយក្នុងកិច្ចការរក្សានោះ ។

**មាត្រា៩៥-** តាមគោលការណ៍អ្នករក្សាត្រូវបានរង្វាន់ ៥ ភាគរយនៃប្រាក់ដែលទារបានមករក្សាទុក និង ៥ ភាគរយនៃប្រាក់ចំណាយ ។

**មាត្រា៩៦-** ការលក់អាចធ្វើទៅបាន ក្នុងកំណត់ ៣០ ថ្ងៃគត់ពីថ្ងៃបិទប្រកាសនៅដីការដែលត្រូវលក់ឡាយឡុងនៅទីផ្សារ នៅទីស្នាក់ការឃុំ និងទីស្នាក់ការតុលាការប្រជាជន ដោយអនុលោមទៅតាមបញ្ញត្តិមាត្រា ៨៦ និ ៨៧ នៃច្បាប់នេះ ។

សំរាប់អចលនវត្ថុដែលស្ថិតនៅក្នុងទីប្រជុំជននៃខេត្ត ឬក្នុងមជ្ឈដ្ឋានដែលត្រូវរៀបចំធ្វើជាក្រុង នោះវិធាននៃការផ្សាយ ត្រូវធ្វើផងដែរតាមសារពត៌មាន តាមវិទ្យុ ឬទូរទស្សន៍ជាដើម ។

**មាត្រា៩៧-** ការលក់នោះ ត្រូវបើឱ្យដេញថ្លៃជាសាធារណះ ជនណាដែលដេញថ្លៃច្រើនជាងគេក្រោយបំផុត ត្រូវបានអចលនវត្ថុដែលដាក់ដេញថ្លៃនោះ ។

**មាត្រា៩៨-** កាលបើបើកឱ្យដេញថ្លៃហើយ ត្រូវឱ្យអុចទៀន ឬភ្លើងបន្តគ្នាទាស់តែទៀន ឬភ្លើងនីមួយ១ នោះឆេះបានកំណត់យ៉ាងតិចណាស់ត្រឹមមួយនាទី ។

លុះទៀន ឬភ្លើងទីបីអុចបន្ត១ គ្នានោះរលត់ផុតកាលណា ទើបត្រូវសំរេចលក់អចលនវត្ថុនោះបានគឺថា បើជនណាដេញថ្លៃហើយគ្មានជនណាដេញថ្លៃឱ្យលើសទៅទៀតក្នុងរវាងដែលទៀន ឬភ្លើងទីបីកំពុងឆេះនោះទេ

ទើបត្រូវសំរេចថាអចលនវត្ថុដែលលក់នោះត្រូវបានជននោះ បើក្នុងវេលាទៀនមួយក្នុងទៀនបីជាតំបូងកំពុងឆេះ ហើយមានគេដេញថ្លៃឡើងតទៅទៀតនោះ នឹងសំរេចលក់បាន លុះត្រាតែទៀនពីរចុងក្រោយរលត់អស់ទៅ គ្មានជនណាដេញថ្លៃឡើងតទៅទៀត ។

**មាត្រា៩៩-** បើក្នុងរវាងទៀន ឬភ្លើងបីគ្មានជនណាដេញថ្លៃទេ ត្រូវទុកម្ចាស់បំណុលដែលប្ដឹងសុំឱ្យរឹបអូសជាអ្នកទិញអចលនវត្ថុដែលលក់ តាមថ្លៃដែលបានកាត់ទុកជាមុន ។

**មាត្រា១០០-** បើហេតុផលណាមួយបណ្ដាលឱ្យលើការលក់ឡាយឡុងនោះទុកទៅថ្ងៃមុខ នោះទុកឱ្យអ្នកដែលបានដេញថ្លៃម្នាក់ឯង ឬអ្នកដែលបានដេញថ្លៃក្រោយគេបំផុតឱ្យរួចពីការទិញរបស់នោះ គឺថាត្រូវទុកថ្លៃដែលជននោះដេញជាអសារឥតការ ។

**មាត្រា១០១-** អ្នកចូលដេញថ្លៃវត្ថុដែលត្រូវលក់ឡាយឡុងនោះ ត្រូវបង់ប្រាក់ធានានៅអ្នកអនុវត្តសាលក្រមដែលចូលសំរួលក់ឡាយឡុងជាមុន ទើបចូលដេញថ្លៃបាន ។ ឯប្រាក់នោះត្រូវគិត ១០ ភាគរយ នៃថ្លៃវត្ថុដែលកាត់ជាមុន ។ ប្រាក់ដែលធានានោះត្រូវប្រគល់ឱ្យម្ចាស់ប្រាក់វិញដោយឥតដកហូតកំរៃអ្វីឡើយ បើអ្នកនោះដេញពុំបានទេ ។ បើអ្នកនោះដេញបានរបស់អ្វីនីមួយៗ អ្នកអនុវត្តសាលក្រមត្រូវយកប្រាក់ធានាទៅដាក់ការិយាល័យក្រលាបញ្ជីគិតជាថ្លៃរបស់ដែលអ្នកនោះដេញបាន ។

**មាត្រា១០២-** បើការលក់ឡាយឡុងធ្វើនៅទីស្នាក់ការតុលាការ ត្រូវដេញប្រាក់ថ្លៃដែលទិញបានទៅឱ្យក្រលាបញ្ជី ។ បើការលក់ឡាយឡុងនៅទីស្នាក់ការឃុំវិញ ត្រូវដេញប្រាក់វត្ថុដែលទិញបានទៅឱ្យប្រធាន ឬអនុ-ប្រធានគណៈកម្មាធិការប្រជាជនឃុំ ។

**មាត្រា១០៣-** អ្នកដេញថ្លៃបានត្រូវបង់ថ្លៃអចលនវត្ថុនោះ ក្នុងរយៈពេល ១០ ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃដេញថ្លៃបាន អ្នកដេញថ្លៃបានត្រូវបង់ពន្ធអ្វីៗ ទាំងអស់នៃការដេញថ្លៃព្រមទាំងសោហ៊ុយទាំងឡាយដែលនាំឱ្យចូលដេញថ្លៃបាន ។ ចំនួនសោហ៊ុយទាំងនោះ ត្រូវបានប្រកាសជាសាធារណៈ ឱ្យបានដឹងជាមុននៅពេលប្រធាន ឬអនុប្រធាននៃគណៈកម្មាធិការប្រជាជនឃុំ ឬចៅក្រមចាត់ការដាក់លក់ ។

កាលបើលក់ធ្វើនៅទីស្នាក់ការតុលាការ នោះត្រូវប្រធានតុលាការជាអ្នកដឹកនាំតែខ្លួនឯងតែម្នាក់ ដោយឥតមានទីប្រឹក្សាតុលាការជួយផងទេ ។

កំណត់ហេតុនៃការដេញថ្លៃ និងត្រូវប្រគល់ឱ្យអ្នកដេញថ្លៃបាន តែនៅពេលក្រោយបង់ថ្លៃ និងសោហ៊ុយទាំងពួងរួចជាស្រេច ។

**មាត្រា១០៤-** អ្នកដេញថ្លៃបានអចលនវត្ថុណាមួយ និងត្រូវបានជាម្ចាស់នៃអចលនវត្ថុនោះ លុះត្រាតែបានសងថ្លៃទិញរបស់នោះរួចស្រេចទាំងអស់ព្រមទាំងថ្លៃសោហ៊ុយដែលខ្លួនត្រូវបង់ ហើយបើគ្មានការតវ៉ាសុំឱ្យដេញថ្លៃឡើងវិញដូចមានចែងក្នុងមាត្រា ១០៧ បើពុំទាន់បង់ថ្លៃទិញរបស់នោះទេ អចលនវត្ថុដែលលក់នោះនៅជារបស់ម្ចាស់ដើមដែលត្រូវរឹបអូសជាដរាប ។

**មាត្រា១០៥-** អ្នកដេញថ្លៃបានអចលនវត្ថុណាមួយត្រូវទទួលកាន់កាប់អចលនវត្ថុនោះ តាំងពីថ្ងៃដែលបានបង់ថ្លៃទិញរួចស្រេច ហើយត្រូវទទួលយកអចលនវត្ថុនោះតាមបែបភាពនៅវេលានោះ មិនអាចតវ៉ាឱ្យមានការធានា និងឱ្យបានសំណងសោហ៊ុយផ្សេងៗ ដែលអចលនវត្ថុនោះមានមកពីមុនៗ នោះបានឡើយ ។

**មាត្រា១០៦-** បើអចលនវត្ថុដែលលក់នោះមានជាប់ពន្ធអារកផ្សេងៗ ពុំទាន់បង់ឱ្យរដ្ឋ នោះត្រូវដកហូតប្រាក់ថ្លៃលក់អចលនវត្ថុនោះបង់ពន្ធអាករទាំងនោះឱ្យរួចស្រេចជាមុនបង្អស់ ។

**មាត្រា១០៧-** ក្នុងរយះពេល ៣ ថ្ងៃ ក្រោយដេញថ្លៃរួច ជនទាំងឡាយអាចនឹងសុំដល់ការិយាល័យក្រលាបញ្ជី ឬអ្នកអនុវត្តសាលក្រមឱ្យលក់ឡាយឡុងវិញបាននូវអចលនវត្ថុដែលលក់រួចហើយនោះ ។ ប៉ុន្តែពាក្យសុំនេះអាចនឹងទទួលបាន លុះត្រាតែអ្នកដែលសុំឱ្យលក់ជាថ្មីឡើងវិញនោះ បានដាក់ប្រាក់ថ្លៃលក់លើកមុននោះគ្រប់ចំនួនទាំងអស់នៅការិយល័យក្រលាបញ្ជី ព្រមទាំងបង់ថែមមួយភាគប្រាំមួយនៃចំនួនប្រាក់ដែលលក់លើសពីមុននោះទៀត ។

**មាត្រា១០៨-** ក្រលាបញ្ជីបើបានទទួលពាក្យសុំយ៉ាងនេះហើយ ត្រូវឱ្យដំណឹងអំពីពាក្យសុំនេះប្រគល់ឱ្យអ្នកអនុវត្តសាលក្រម ឱ្យយកទៅប្រគល់ឱ្យអ្នកទិញលើកមុន និងម្ចាស់បំណុលដែលប្តឹងសុំឱ្យលក់ ហើយដែលមានចុះឈ្មោះព្រមទាំងកូនបំណុលដែលត្រូវរឹបអូសនោះផង ។

**មាត្រា១០៩-** ប្រធានតុលាការត្រូវចេញដីកាកំរិតថ្ងៃ ខែ ដែលត្រូវលក់ឡាយឡុងជាថ្មីទៀតឡើងវិញនោះហើយបង្គាប់អោយអ្នកអនុវត្តសាលក្រមធ្វើប្រកាសអោយដំណឹងអំពីការលក់ជាថ្មីនោះផង។

**មាត្រា១១០-** ការលក់ជាថ្មីឡើងវិញនោះត្រូវលក់ក្នុងរវាងមួយខែ គិតពីថ្ងៃដាក់ពាក្យសុំដល់ការិយាល័យក្រលាបញ្ជី ឬ ដល់ដៃអ្នកអនុវត្តសាលក្រម ។

**មាត្រា១១១-** បើគ្មានជនណាសុំអោយលក់ជាថ្មីឡើងវិញ ដោយហ៊ានអោយថ្លៃលើសមួយភាគប្រាំមួយនៃថ្លៃលក់លើកមុខទេ ហើយបើដល់កំណត់១០ ថ្ងៃគិតពីថ្ងៃលក់មក អ្នកទិញដែលបានដាក់ប្រាក់ធានារួចហើយពុំបានបង់ប្រាក់ថ្លៃទិញគ្រប់ចំនួន ព្រមទាំងថ្លៃសោហ៊ុយឯទៀតដែលខ្លួនត្រូវបង់នោះផងទេ នោះកូនបំណុលដែលត្រូវរឹបអូស និងម្ចាស់បំណុលដែលប្តឹងសុំអោយលក់ ហើយនិងម្ចាស់បំណុលឯទៀតដែលមានឈ្មោះ និយាយរួមគឺ

ជនទាំងឡាយណាដែលមានប្រយោជន៍ក្នុងរឿងនេះ អាចនិងប្តឹងសុំអោយលក់ជាថ្មីឡើងវិញ ដោយហេតុអ្នកទិញពុំបានបង់ថ្លៃ។

**មាត្រា១១២ -** ឯការលក់ក្រោយនេះ គឺត្រូវអោយលក់ពីថ្លៃដែលបានអោយដេញឡើងនៅពេលលក់លើកមុន។

**មាត្រា១១៣ -** បើលក់ឡាយឡុងលើកក្រោយនេះ បានថ្លៃតិចជាងពីថ្លៃលក់លើកមុន ទាំងថ្លៃដើមនិងសោហ៊ុយផង នោះត្រូវបង្ខំអ្នកដែលបានទិញលើកមុន ហើយដែលពុំបានសងថ្លៃគ្រប់ផ្លូវច្បាប់ និងបង្ខំដល់រូបកាយផងអោយសងដល់ចំនួនប្រាក់ទាំងប៉ុន្មានដែលបានកើតចេញពីការលក់លើកទី១ និង ការលក់លើកទី២ ដោយគិតពីសោហ៊ុយផង ។

បើលក់លើកក្រោយនេះបានថ្លៃច្រើនលើសពីថ្លៃលក់លើកមុន ចំនួនប្រាក់ដែលលើសនោះត្រូវយកទៅអោយម្ចាស់បំណុលដែលមានចុះឈ្មោះ បើនៅសល់ត្រូវប្រគល់អោយកូនបំណុល ។

អ្នកទិញលើកមុនអាចទាមទារសោហ៊ុយ ដែលខ្លួនបានបង់ក្នុងការទិញលើកមុននោះរួចទៅហើយពីអ្នកទិញ លើកក្រោយក្តីពីម្ចាស់បំណុលក្តី ពីកូនបំណុលដែលត្រូវរឹបអូសក្តី។

សោហ៊ុយនិងប្រាក់ធានានោះ ត្រូវបានទៅម្ចាស់បំណុលដែលមានចុះឈ្មោះ និង កូនបំណុលដែលត្រូវរឹបអូសដូចមានចែងក្នុងវាក្យខ័ណ្ឌ។

**មាត្រា១១៤ -** ចំពោះការសុំអោយរើលក់ឡាយឡុងជាថ្មីឡើងវិញ ត្រូវអ្នកដែលមានប្រយោជន៍ក្នុងរឿងនេះធ្វើពាក្យប្តឹងទៅតុលាការ។

**មាត្រា១១៥ -** តុលាការជំនុំជំនះលើពាក្យប្តឹងសុំនេះនៅវេលាជំនុំជំនះខាងមុខដ៏ខ្លី ក្រោយពីបានកោះហៅដ៏ត្រឹមត្រូវឱ្យអោយអ្នកទិញលើកមុនដែលពុំបានសងថ្លៃគ្រប់ចូលមកជាចុងចម្លើយ

បើតុលាការចេញសាលក្រមសំរេចសេចក្តីតាមពាក្យសុំនោះ ត្រូវឱ្យចាត់របៀបលក់ឡាយឡុងជាថ្មីចាប់តាំងពីថ្ងៃបិទប្រកាសផ្សាយតទៅ។

**មាត្រា១១៦ -** ១០ ថ្ងៃមុនថ្ងៃលក់ឡាយឡុង ជនដែលមានប្រយោជន៍ក្នុងការរឹបអូសអចលនវត្ថុជាអាទិម្ចាស់បំណុលដែលមានចុះឈ្មោះ និង ម្ចាស់បំណុលដែលគ្រាន់តែមានសំបុត្រសាកម្មទណ្ឌធម្មតា ប៉ុន្តែមានសាលក្រមជាស្រេចដាច់ខាត អាចប្តឹងសុំឱ្យបដិសេធការរឹបអូសអចលនវត្ថុបាន។

**មាត្រា១១៧ -** ប័ណ្ណប្រកាសលក់ឡាយឡុងដែលយកទៅបិទ ហើយដែលមានចែងលក្ខ័ណ្ឌខាងលើចាំបាច់ត្រូវតែសរសេរជាអក្សរធំៗ មើលឃើញស្រួល ដើម្បីឱ្យមហាជនចាប់អារម្មណ៍ចំពោះការអស់សិទ្ធិ និងសុំបដិសេធ ។

**មាត្រា១១៨-** បើការលក់ធ្វើនៅទីស្នាក់ការតុលាការក្ដី ឬ នៅទីស្នាក់ការគណៈកម្មាធិការឃុំក្ដី ប្រធានតុលាការសំរេចយល់ព្រម ឬ ទាត់ចោលពាក្យបណ្ដឹងសុំបដិសេធដោយចេញដីកាកិច្ចការប្រញាប់ក្នុងរយៈពេល១០ ថ្ងៃគិតពីថ្ងៃដាក់ពាក្យសុំត្រឹមត្រូវ ដល់ថ្ងៃកំណត់ដើម្បីលក់ឡាយឡុង តែត្រូវសំរេចក្នុងពេលដ៏គួរដើម្បីឱ្យប្រធានគណៈកម្មាធិការឃុំបានដឹងអំពីសេចក្ដីសំរេចមុនថ្ងៃកំណត់អោយលក់ ។

បើពាក្យសុំត្រូវទាត់ចោលនោះត្រូវឱ្យដំណឹងភ្លាមទៅអ្នកអនុវត្តសាលក្រម ។ អ្នកអនុវត្តសាលក្រមត្រូវឱ្យដំណឹងទៅប្រធានគណៈកម្មាការឃុំ អំពីរឿងនេះហើយការលក់ត្រូវធ្វើតទៅ ។ សោហ៊ុយទាំងឡាយដែលបណ្ដាលឱ្យមានឧបត្ថិហេតុនេះ ត្រូវជាបន្ទុករបស់ភាគីអ្នកចាញ់ក្ដី ។

ក្នុងករណីដែលការរឹបអូសត្រូវបដិសេធដោយបណ្ដាលមកពីខុសនឹងទំរង់ច្បាប់ប្រធានតុលាការត្រូវសំរេចថាតើចាប់តាំងពីកិច្ចត្រង់ណាទៅនីតិវិធីត្រូវធ្វើឡើងវិញ ។

**មាត្រា១១៩-** បើការរឹបអូសត្រូវបដិសេធដោយទាស់ខុសនឹងគតិច្បាប់ គឺថាការរឹបអូសនោះមិនគប្បីឱ្យធ្វើដោយមូលហេតុអ្វីមួយ នោះការលក់ឡាយឡុងត្រូវលើកទៅថ្ងៃមុខរហូតដល់មានសេចក្ដីសំរេចអំពីទំនាស់ជាអង្គសេចក្ដី ។

**មាត្រា១២០-** ជនណាដែលតវ៉ាថា អចលនវត្ថុណាមួយជារបស់ខ្លួន ត្រូវធ្វើពាក្យប្ដឹងតវ៉ា ក្នុងរវាង ៦ ខែ គិតតាំងពីថ្ងៃលក់ឡាយឡុង ។ បើហួសកំណត់នេះ ពាក្យនោះត្រូវទុកជាអសារឥតការ ។

បើផុតកំណត់នេះហើយជនដែលប្រកាន់ខ្លួនជាម្ចាស់អចលនវត្ថុណាមួយមានអំណាចត្រឹមតែប្ដឹងទារសោហ៊ុយជម្ងឺចិត្តពីជនដែលធ្វើឱ្យខ្លួនបាត់បង់អំណាចកម្មសិទ្ធិលើអចលនវត្ថុនោះតែប៉ុណ្ណោះ ។

**មាត្រា១២១-** បើជនណាប្ដឹងតវ៉ាថាអចលនវត្ថុណាមួយជារបស់ខ្លួនបានជូនពាក្យប្ដឹងតវ៉ានោះមុនថ្ងៃដែលលក់ឡាយឡុង ពាក្យប្ដឹងនោះមិនបណ្ដាលឱ្យខានលក់ឡាយឡុងទេ ។ ប៉ុន្តែតុលាការអាចសំរេចដោយឯកឯង ឬតាមពាក្យប្ដឹងពីគូក្ដីបង្អង់លក់ឡាយឡុងសិនក៏បាន ដូចមានបញ្ញត្តិមាត្រា ១១៦ និងមាត្រាតទៅ ។

**មាត្រា១២២-** បើគ្មានពាក្យប្ដឹងតវ៉ាសុំកុំឱ្យប្រគល់ប្រាក់ថ្លៃវត្ថុដែលលក់នោះទេ ត្រូវឱ្យកត់ឈ្មោះម្ចាស់បំណុលដែលប្ដឹងសុំឱ្យរឹបអូសនៅក្នុងសាលក្រមដែលសំរេចពីការលក់ឡាយឡុង ដើម្បីឱ្យមកទទួលយកប្រាក់ថ្លៃវត្ថុដែលលក់បានរហូតដល់គ្រប់ចំនួនប្រាក់ដែលជំពាក់ ក្រោយពីបានកាត់សោហ៊ុយ និងពន្ធដារផ្សេងៗរួចហើយប្រសិនបើមាន ។

បើមានពាក្យតវ៉ាសុំកុំឱ្យប្រគល់ប្រាក់ថ្លៃវត្ថុដែលលក់បាននោះ ប្ដឹងដល់ប្រធានគណៈកម្មាធិការឃុំ ក្រលាបញ្ជី ឬអ្នកអនុវត្តសាលក្រម នោះប្រាក់ដែលបានមកពីការលក់ឡាយឡុងត្រូវប្រគល់ទៅឱ្យក្រលាបញ្ជីរក្សាទុក ។

អ្នកអនុសាលក្រម ឬប្រធានគណៈកម្មាធិការឃុំដែលបានទទួលប្រាក់បានមកពីការលក់ឡាយឡុង ត្រូវតែប្រគល់ប្រាក់នោះទៅឱ្យក្រលាបញ្ជី ក្រលាបញ្ជីត្រូវទទួលប្រាក់នោះទុក ។

ឯប្រាក់នោះឯងត្រូវទុកនៅក្រឡាបញ្ជី លុះត្រាតុលាការសំរេចពីពាក្យប្តឹងតវ៉ានោះរួចហើយស្រេច បណ្តឹងតវ៉ានេះត្រូវប្រធានតុលាការ ឬចៅក្រមដែលប្រធានចាត់តាំងសំរេចក្នុងរវាង ១ ខែ ។

**មាត្រា១២៣ -** ការសំរេចក្តីនោះត្រូវការដោះស្រាយដែលប្រធានតុលាការ ឬចៅក្រមដែលប្រធានតុលាការចាត់តាំងបានសុំតាមច្បាប់ ចំពោះបំណុលនោះមានសំបុត្របញ្ចាំហៅថា ហ៊ីប៉ូតែ្ទក ឬបំណុលដែលមានឯកសិទ្ធិឯទៀតតាមសមធមិ ចំពោះបំណុលនោះមានតែសំបុត្រសាកម្មទណ្ឌធម្មតា សេចក្តីសំរេចនោះត្រូវចុះក្នុងកំណត់ហេតុដែលត្រូវធ្វើក្នុងគ្រានោះ ហើយត្រូវរក្សាដើមកំណត់ហេតុនោះនៅក្នុងការិយាល័យក្រលាបញ្ជី ។

**មាត្រា១២៤ -** បើគូក្តីមិនព្រមព្រៀងគ្នា តាមសេចក្តីសំរេចនោះទេ ប្រធានតុលាការ ឬចៅក្រមដែលទទួលចាត់ការរឿងនោះត្រូវប្រាប់អ្នកដែលប្តឹងតវ៉ាឱ្យប្តឹងតវ៉ាទៅតុលាការ ។

## ជំពូកទី ៣

## អំពីការដាក់គុកបង្ខំដល់រូបកាយ

**មាត្រា១២៥ -** ការដាក់គុកបង្ខំដល់រូបកាយនេះ គឺជាការបង្ខំកូនបំណុលដែលរឹងរូសឱ្យបំពេញកិច្ចសន្យារបស់ខ្លួន ។

**មាត្រា១២៦ -** ការដាក់គុកបង្ខំដល់រូបកាយនេះ ទោះបីកូនបំណុលបានទទួលរងរួចហើយក៏មិនបណ្តាលឱ្យកូនបំណុលនោះរួចខ្លួនពីជំពាក់គេទេ បើបំណុលមិនបានរលត់ដោយបានសងជាប្រាក់កាស ឬដោយប្រការណាមួយដែលច្បាប់សំរេចទុកនោះទេ បំណុលនោះត្រូវនៅជំពាក់តទៅ ។

**មាត្រា១២៧ -** ការដាក់គុកបង្ខំដល់រូបកាយមិននាំឱ្យរាំងស្ទះ ឬអាក់ខានដល់ការទារប្រាក់ដែលធំធាត់និងការរឹបអូសរបស់ទ្រព្យទេ ។ ម្ចាស់បំណុលមានសិទ្ធិពេញទីក្នុងការសុំឱ្យដាក់គុកកូនបំណុលបង្ខំឱ្យទារប្រាក់ផងហើយសុំឱ្យរឹបអូសយករបស់ទ្រព្យព្រមជាមួយផងដែរក៏បាន ។

**មាត្រា១២៨ -** ការដាក់គុកដល់រូបកាយនេះ តុលាការគ្មានសិទ្ធិអនុញ្ញាតិឱ្យដោយឯកឯងទេ តែត្រូវមានពាក្យប្តឹងសុំពីម្ចាស់បំណុល ឬក៏សុំប្តឹងដោយមាត់ទទេនៅពេលជំនុំជំរះក៏បានដែរ បើប្តឹងសុំមាត់ទទេដូច្នេះត្រូវឱ្យចុះសេចក្តីសុំនោះនៅក្នុងសៀវភៅសំរាប់កត់ហេតុជំនុំជំរះ ។

**មាត្រា១២៩ -** ការដាក់គុកបង្ខំដល់រូបកាយនេះ អាចនឹងសុំទៅទល់នឹងពេលជំនុំជំរះចេញសាលក្រមក៏បាន ។

**មាត្រា១៣០ -** តុលាការអាចនឹងបង្គង់ឱ្យកូនបំណុលរកប្រាក់សងក្នុងរវាង ៦ ខែ បានតែត្រូវឱ្យអធិប្បាយហេតុឱ្យសព្វគ្រប់ជាសំអាងក្នុងសាលក្រម ។ ក្នុងរយះពេលកំណត់នេះ ការដាក់គុកបង្ខំដល់រូបកាយពុំអាចធ្វើបានឡើយ ។

**មាត្រា១៣១ -** ការដាក់គុកបង្ខំដល់រូបកាយកូនបំណុលត្រូវដាក់ក្នុងពន្ធនាគារខាងលំនៅរបស់កូនបំណុល ។

**មាត្រា១៣២ -** សាលាជំនុំជំរះក្តីមិនត្រូវអនុញ្ញាតិឱ្យមានការដាក់គុកបង្ខំដល់រូបកាយ :

១. អនីតិជនអាយុតិចជាង ១៨ ឆ្នាំ

២. មនុស្សចាស់មានអាយុលើសពី ៦៥ ឆ្នាំ ចំពោះស្ត្រី និងលើសពី ៧០ ឆ្នាំ ចំពោះបុរស

៣. ជនពិការ

៤. នារីមានផ្ទៃពោះ និងនារីមានកូនអាយុតិចជាង ៣ ឆ្នាំ

៥. ជនអ្នកធានា

៦. ជនជាញាតិរបស់ម្ចាស់បំណុលរហូតដល់ជួរទី ៤ រាប់ទាំងជួរនេះផង

៧. កូនបំណុលដែលជំពាក់តិចជាងមួយសែនរៀល " ១០០ ០០០ រៀល "

៨. ជនជាទាយាទរបស់កូនបំណុល ។

**មាត្រា១៣៣ -** ថេរៈវេលានៃការដាក់គុកបង្ខំដល់រូបកាយ ត្រូវធ្វើទៅតាមសមាមាត្រ នៃចំនួនប្រាក់ជំពាក់ដែលមិនសង ថេរៈវេលានេះត្រូវកំណត់ដូចតទៅ :

- មួយខែ សំរាប់ប្រាក់ជំពាក់ពី ១០០. ០០០ រ. ០០ ដល់ ២០០. ០០០ រ.០០
- ពីរខែ សំរាប់ប្រាក់ជំពាក់ពី ២០០.០០០ រ.០០ ដល់ ៤០០. ០០០ រ. ០០
- បីខែ សំរាប់ប្រាក់ជំពាក់ពី ៤០០. ០០០ រ. ០០ ដល់ ៦០០. ០០០ រ. ០០
- បួនខែ សំរាប់ប្រាក់ជំពាក់ពី ៦០០. ០០០ រ. ០០ ដល់ ១.២០០. ០០០ រ. ០០
- ប្រាំខែ សំរាប់ប្រាក់ជំពាក់ពី ១.២០០. ០០០ រ. ០០ ដល់ ៣.០០០. ០០០ រ. ០០
- ប្រាំមួយខែ សំរាប់ប្រាក់ជំពាក់ពី ៣. ០០០.០០០ រ. ០០ ដល់ ៦. ០០០. ០០០ រ. ០០
- ប្រាំបីខែ សំរាប់ប្រាក់ជំពាក់ពី ៦. ០០០. ០០០ រ.០០ ឡើងទៅ ។

**មាត្រា១៣៤ -** បើកូនបំណុលដែលទទួលការដាកគុកបង្ខំដល់រូបកាយនោះមានជំងឺ ហើយទុកឱ្យនៅក្នុងគុកតទៅនាំឱ្យអន្តរាយជីវិត តាមពាក្យសុំរបស់កូនបំណុល ឬរបស់ប្រធានពន្ធនាគា ដោយមានសំបុត្រពេទ្យជូនភ្ជាប់មកជាមួយផងនោះ ប្រធានតុលាកាត្រូវដោះលែងខ្លួនកូនបំណុលតាមពាក្យសុំនោះ ។

**មាត្រា ១៣៥:** ម្ចាស់បំណុល បើទុកជាកូនបំណុលមិនទាន់សងប្រាក់ជំពាក់ អាចប្តឹងសុំ អោយដោះកូនបំណុលពីពន្ធនាគារ បាន ។

បើមានពាក្យប្តឹងសុំពីម្ចាស់បំណុលដូច្នេះ ប្រធានតុលាការត្រូវអោយដោះលែងតាមពាក្យសុំនោះ ។

**មាត្រា ១៣៦:** ការដាក់គុកបង្ខំដល់រូបកាយត្រូវធ្វើតាមពាក្យប្តឹងពីម្ចាស់បំណុល ។ អ្នកអនុវត្តសាលក្រម ត្រូវជូនពាក្យដែលប្តឹងដាក់គុកបង្ខំដល់រូបកាយ ទៅប្រធានតុលាការ ព្រមជាមួយនឹងលិខិតឯទៀតអមជាមួយផង គឺសាលក្រមដែលអនុញ្ញាតិបង្ខំដល់រូបកាយ និង បង្កាន់ដៃដាក់ប្រាក់ថ្លៃអាហារជូនរដ្ឋសំរាប់មួយខែយ៉ាងតិច ។

**មាត្រា ១៣៧:** ប្រធានតុលាការ កាលបើពិនិត្យឃើញមានលិខិតសព្វគ្រប់ហើយ ត្រូវបង្គាប់អោយនាំកូនបំណុលទៅដាក់គុក ។

**មាត្រា ១៣៨:** បើកូនបំណុលតវ៉ាពីរឿងដាក់គុកនេះ អ្នកអនុវត្តសាលក្រម ត្រូវនាំកូនបំណុលនោះ ទៅប្រធានតុលាការ ។ ប្រធានតុលាការត្រូវសំរេចដោយដីកាអំពីការតវ៉ាដោយលិខិត ឬ ដោយមាត់ទទេ របស់កូនបំណុលនោះ ។ ឯអ្នកអនុវត្តសាលក្រម ត្រូវតំណាងម្ចាស់បំណុលក្នុងពេលសំរេចសេចក្តីនោះ ។

**មាត្រា ១៣៩:** បើហេតុដែលកូនបំណុលយកមកអាងនោះមិនទុកជាបានការទេ ប្រធានតុលាការ ត្រូវចេញដីកាបង្គាប់ អោយដាក់គុកកូនបំណុលនោះ ។ ចំណែកឯប្រធានពន្ធនាគារ កាលបើឃើញដីកានេះហើយ ត្រូវទទួលកូនបំណុលដែលត្រូវដាក់គុកនោះ ។ ដីកានោះត្រូវអនុវត្តតាមភ្លាម ។

**មាត្រា ១៤០:** ថ្លៃអាហារ ត្រូវតែបង់មុនជាប គឺមួយខែ អោយបង់ម្តង ។

**មាត្រា ១៤១:** បើម្ចាស់បំណុលភ្លេចបង់ ឬ ពុំបានបង់ថ្លៃអាហារនេះ ត្រូវអោយដោះលែងកូនបំណុលនៅវេលាមួយថ្ងៃក្រោយដែលផុតកំណត់ខែដែលបានបង់ថ្លៃអាហារហើយនោះ ។

**មាត្រា ១៤២:** បើម្ចាស់បំណុលខ្លួនឯង បានប្តឹងសុំអោយដោះលែងកូនបំណុលពីគុក ឬ បើត្រូវដោះកូនបំណុលនោះពីគុកដោយម្ចាស់បំណុលមិនបានបង់ប្រាក់ថ្លៃអាហារនោះ ម្ចាស់បំណុល មិនអាចប្តឹងសុំអោយយក កូនបំណុលនោះមកដាក់បង្ខំជាថ្មីទៀតពីប្រាក់ជំពាក់ដដែលនោះពុំបានឡើយ ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័ត នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩២ នាសម័យប្រជុំវិសាមញ្ញនៃនីតិកាលទី១ ។

ភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ ១៩៩២

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខា និងត្រា: ជា ស៊ីម

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

អគ្គលេខាក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និងត្រា: ចាន់ វ៉ែន

លេខ: ៥៤ ច.ល

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ១៩៩២

ប្រធានមន្ទីរក្រសួងយុត្តធម៌

អនុប្រធាន: តុង ពាវ